ទីស្តីការក្រសួងយុត្តិធម៌
លេខ ៦០៦ កណ-៩៦

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ជម្រាបមក</u>**

**លោកប្រធានតុលាការខេត្តកំពត**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** សេចក្តីណែនាំស្តីពីការអនុវត្តសាលក្រម ។

**<u>យោង:</u>** លិខិតរបស់តុលាការខេត្តកំពតលេខ ១៥៥ បេ-៩៦ ចុះថ្ងៃទី១៨-០៣-៩៦ ។

ខ្ញុំសូមជម្រាបលោកជ្រាបថា ការអនុវត្តសាលក្រមឬសាលដីកាស្ថាពរជាភារកិច្ចរបស់តុលាការខេត្ត-ក្រុង នៃដែនដីសមត្ថកិច្ច ក្រសួងយល់ឃើញថា បើមានសាលក្រមឬសាលដីកាស្ថាពរហើយនោះតុលាការខេត្ត-ក្រុង ត្រូវតែអនុវត្តចាប់ផ្តើមពីសេចក្តីជូនដំណឹងនូវសេចក្តីសម្រេចនៃសាលក្រម ឬសាលដីកានោះដោយមានចម្លងសាលក្រមឬសាលដីកាដែលត្រូវអនុវត្តនោះទាំងមូលជូនទៅអ្នកចាញ់ក្តីជាដំណឹង ការចម្លងសាលក្រមឬសាលដីកាទាំងមូលភ្ជាប់ជាមួយលិខិតជូនដំណឹងនេះគឺធ្វើចំពោះតែសាលក្រមឬសាលដីកាណា ដែលសម្រេចសេចក្តីទាក់ទិនដល់អចលនវត្ថុប៉ុណ្ណោះ ។ ដោយឡែកចំពោះសាលក្រមឬសាលដីកាដែលទាក់ទិនលើចលនវត្ថុ អ្នកអនុវត្តសាលក្រមគ្រាន់តែចម្លងសម្រង់សាលក្រមឬសម្រង់សាលដីកា ជូនដំណឹងជាការគ្រប់គ្រាន់ ហើយដោយមានការកំណត់ពេលវេលាឱ្យអនុវត្តដោយស្ម័គ្រចិត្តផង ។ បន្ទាប់មកក្នុងករណីមិនបានសម្រេច ត្រូវធ្វើសេចក្តីបង្គាប់ឱ្យអនុវត្តដែលអាជ្ញាសាលាត្រូវកំណត់ពេលវេលា ឱ្យបានសមរម្យល្មមសម្រាប់ឱ្យអ្នកទទួលអនុវត្តអាចអនុវត្តបានតាមទំហំការងារ ដោយយោងតាមសេចក្តីជូនដំណឹងដែលបានធ្វើសព្វគ្រប់រួចហើយ ។

សេចក្តីជូនដំណឹងនិងសេចក្តីបង្គាប់នេះ អាជ្ញាសាលាអាចធ្វើម្តងឬពីរដងបានដោយនៅដំណាក់កាលចុងក្រោយត្រូវធ្វើរបាយការណ៍ស្តីពីសេចក្តីបង្គាប់របស់ខ្លួន ម្តងឬពីរដងដែលមិនបានសម្រេចនោះសុំយោបល់ទៅប្រធានតុលាការ ដើម្បីចេញសេចក្តីបង្គាប់ជាថ្មី កំណត់ពេលជាថ្មីជាក់លាក់ ដើម្បីប្រុងប្រៀបកំលាំងដោយមានការឯកភាពពីព្រះរាជអាជ្ញាឱ្យបានសព្វគ្រប់ លុះដល់ថ្ងៃកំណត់ត្រូវចុះទៅអនុវត្តនៅដំណាក់កាលចុងក្រោយតែម្តង ដោយចាត់វិធានការណតាមផ្លូវច្បាប់ដើម្បីអនុវត្តឱ្យបានសម្រេចដាច់ខាត ។

ដើម្បីឱ្យកាន់តែប្រាកដក្នុងការងាររបស់ខ្លួន សូមលោកប្រធាននិងអ្នកអនុវត្តសាលក្រមស្រាវជ្រាវសិក្សារៀនសូត្រ អំពីច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមឱ្យបានល្អិតល្អន់និងយល់ច្បាស់ រួចហើយចាត់ការអនុវត្តឱ្យបានត្រឹមត្រូវនិង ហ្មត់ចត់ប្រាកដប្រជាតាមច្បាប់តទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>

-តុលាការ និងអយ្យការខេត្ត-ក្រុង
-តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-តុលាការ និងអយ្យការអមតុលាការយោធា
-ដើម្បីជ្រាប នឹងអនុវត្ត